ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីទំហំ ២ ៩៨៥ ៤៧២ (ពីរលានប្រាំបួនរយប៉ែតសិបប្រាំពាន់បួនរយចិតសិបពីរ) ម៉ែត្រក្រឡា ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក

(បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ .-**

ប្រគល់ដីទំហំ ២ ៩៨៥ ៤៧២ (ពីរលានប្រាំបួនរយប៉ែតសិបប្រាំពាន់បួនរយចិតសិបពីរ) ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ជូនក្រសួងការពារជាតិដើម្បីចាត់ចែងរៀបចំអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងប្រើប្រាស់ជាទីកន្លែងដឹកនាំបញ្ជាយុទ្ធសាស្ត្រយូរអង្វែង។

**មាត្រា ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ




| ID | E | N |
|---|---|---|
| 1 | 4770[illegible] | 1286169.450 |
| 2 | 477399.140 | 1286504.310 |
| 3 | 479178.215 | 1284531.201 |
| 4 | 478799.471 | 1284457.694 |
| 5 | 478577.220 | 1284362.444 |
| 6 | 478363.357 | 1284118.481 |
| 7 | 478164.008 | 1283978.610 |
| 8 | 477946.238 | 1283940.081 |
| 9 | 476798.266 | 1285213.000 |
| 10 | 476809.169 | 1285261.177 |
| 11 | 476829.615 | 1285424.748 |
| 12 | 476830.209 | 1285488.683 |
| 13 | 476919.895 | 1285516.684 |
| 14 | 476918.279 | 1285535.235 |
| 15 | 476903.982 | 1285601.672 |
| 16 | 476891.894 | 1285668.224 |
| 17 | 476842.071 | 1285661.132 |
| 18 | 476764.782 | 1285659.941 |
| 19 | 476770.458 | 1285885.875 |
| 20 | 476835.881 | 1285896.469 |
| 21 | 476899.501 | 1285860.828 |
| 22 | 476943.951 | 1285859.241 |
| 23 | 476986.813 | 1285883.053 |
| 24 | 477016.976 | 1285911.628 |
| 25 | 477028.089 | 1285929.091 |
| 26 | 477039.201 | 1285954.491 |
| 27 | 477039.201 | 1286003.704 |
| 28 | 477035.497 | 1286039.687 |
| 29 | 477034.439 | 1286056.620 |
| 30 | 477038.672 | 1286075.670 |
| 31 | 477050.314 | 1286080.962 |
| 32 | 477103.761 | 1286085.258 |


Projection, UTM, Zone48N
Datum, WGS 1984
1:30,000
2985472m²
2656.74
1714.11
| ID | E | N |
|---|---|---|
| 1 | 477027.833 | 1286169.450 |
| 2 | 477399.140 | 1286504.310 |
| 3 | 479178.215 | 1284531.201 |
| 4 | 478799.471 | 1284457.694 |
| 5 | 478577.220 | 1284362.444 |
| 6 | 478363.357 | 1284118.481 |
| 7 | 478164.008 | 1283978.610 |
| 8 | 477946.238 | 1283940.081 |
| 9 | 476798.266 | 1285213.000 |
| 10 | 476809.169 | 1285261.177 |
| 11 | 476829.615 | 1285424.748 |
| 12 | 476830.209 | 1285488.683 |
| 13 | 476919.895 | 1285516.684 |
| 14 | 476918.279 | 1285535.235 |
| 15 | 476903.982 | 1285601.672 |
| 16 | 476891.894 | 1285668.224 |
| 17 | 476842.071 | 1285661.132 |
| 18 | 476764.782 | 1285659.941 |
| 19 | 476770.458 | 1285885.875 |
| 20 | 476835.881 | 1285896.469 |
| 21 | 476899.501 | 1285860.828 |
| 22 | 476943.951 | 1285859.241 |
| 23 | 476986.813 | 1285883.053 |
| 24 | 477016.976 | 1285911.628 |
| 25 | 477028.089 | 1285929.091 |
| 26 | 477039.201 | 1285954.491 |
| 27 | 477039.201 | 1286003.704 |
| 28 | 477035.497 | 1286039.687 |
| 29 | 477034.439 | 1286056.620 |
| 30 | 477038.672 | 1286075.670 |
| 31 | 477050.314 | 1286080.962 |
| 32 | 477103.761 | 1286085.258 |